# ការសម្ភាសន៍របស់អ្នកមីង ជួន យ៉េត

**កៈ អ្នកសម្ភាសន៍ឈ្មោះ ហេង សុវណ្ណានរិទ្ធ   ខៈ អ្នកត្រូវគេសម្ភាសន៍ឈ្មោះជួន យ៉េត**

## ពត៌មានសង្ខេបរបស់អ្នកមីង ជួន យ៉េត

សព្វថ្ងៃនេះអ្នកមីងជួន យ៉េតមានអាយុ៥៥ឆ្នាំហើយ គាត់មានបងប្អូនចំនួន៥នាក់ហើយគាត់ជាកូនទី២ នៅក្នុងគ្រួសាររបស់គាត់។ ជីវិតកាលពីវ័យកុមាររបស់អ្នកមីងត្រូវបានបាត់បង់ភាពសប្បាយរីករាយ ដោយសារតែសម័យកាលដ៏ឃោរឃៅរ យង់ឃ្នង់ជាទីបំផុតគឺសម័យប៉ុល ពត។ គាត់មិនបានរៀនសូត្រ ឲ្យមានចំណេះដឹង គាត់ត្រូវធ្វើការងារលំបាកជាច្រើនដើម្បីទទួលបានអាហារបរិភោគចិញ្ចឹមជីវិត គាត់ត្រូវរស់នៅដោយភាពភ័យ ខ្លាច។ បន្ទាប់ពីប៉ុល ពតគាត់ត្រូវខិតខំធ្វើការនេសាទដើម្បីចិញ្ចឹមប្អូនៗនិង ម្ដាយរបស់គាត់ គាត់ជាស្រ្តីម្នាក់រឹងមាំនិងគួរឲ្យកោតសរសើរជាខ្លាំង។

កៈ បាទជាដំបូងខ្ញុំសូមថ្លែងអំណរគុណដល់មីងដែលបានឲ្យខ្ញុំសម្ភាសន៍ពីប្រវិត្តរបស់មីង ហើយការសម្ភាសន៍ណឹងត្រូវបានរៀបចំដោយសាកលវិទ្យាល័យមួយដែលមានឈ្មោះថាព្រីហាំយ៉ង់ដែលនៅឯសហរដ្ឋអាមេរិក។ បាទ គោលបំណងរបស់សាកលវិទ្យាល័យគឺចង់សម្ភាសន៍ប្រវិត្តប្រជាជនខ្មែរ ដើម្បីរក្សារទុកប្រវិត្តប្រជាជនខ្មែរដើម្បីឲ្យកូនចៅជំនាន់ក្រោយរបស់មីងអាចស្គាល់ពីប្រវិត្តរបស់ជីដូនជីតាហើយរៀនអំពីប្រវិត្តរបស់ពួកគាត់ណាមីង បាទ ហើយចឹងនៅពេលដែលខ្ញុំសម្ភាសន៍មីងចប់ ខ្ញុំនឹងដាក់ការសម្ភាសន៍របស់មីងណឹងនៅក្នុងវេបសាយរបស់សាលាដែលមានឈ្មោះថា www.cambodiaoralhistory.byu.edu ណាមីង ចឹងតើមីងយល់ព្រមឲ្យខ្ញុំដាក់សម្ភាសន៍របស់មីងចូលទៅក្នុងវេបសាយរបស់សាលាទេមីង?

ខៈ ព្រមតើ។

កៈ បាទសម្រាប់ថ្ងៃខែដែលខ្ញុំសម្ភាសន៍មីងនេះគឺ នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០ ហើយការសម្ភាសន៍នេះត្រូវបានធ្វើឡើងនៅភូមិចុងឃ្មៀស សង្កត់ចុងឃ្មៀស ស្រុកសៀមរាប ខេត្តសៀមរាបណាមីង ហើយខ្ញុំជាអ្នកសម្ភាសន៍ឈ្មោះ ហេង សុវណ្ណានរិទ្ធ អញ្ចឹងខ្ញុំចង់សួរថាតើមីងមានឈ្មោះពេញឈ្មោះអ្វីដែរមីង?

ខ៖ ចាសឈ្មោះជួន យ៉េត។

ក៖ ចុះអ្នកមីងមានឈ្មោះហៅក្រៅទេអ្នកមីង?

ខ៖ អត់មានទេ។

ក៖ ហើយឆ្នាំនេះមីងមានអាយុប៉ុន្មានហើយមីង?

ខ៖ ខ្ញុំនេះខ្ញុំចូល៥៥ឆ្នាំហើយ។

ក៖ ចុះអ្នកមីងចាំថ្ងៃខែឆ្នាំកំណើតអ្នកមីងបានទេមីង?

ខ៖ ខ្ញុំចាំ ចាសចាំខ្ញុំកើត ខែស្រាពណ៍ ថ្ងៃពុធ។

ក៖ ចុះឆ្នាំណាដែរអ្នកមីង?

ខ៖ ឆ្នាំមរមីចាស។

ក៖ ចុះឆ្នាំបារាំងអ្នកមីងចាំទេ?

ខ៖ អត់ចាំ ព្រោះខ្ញុំអត់សូវចេះអក្សរអត់បានរៀន។

ក៖ ចុះអ្នកមីងមានស្រុកកំណើតនៅឯណាដែរអ្នកមីង?

ខ៖ ស្រុកកំណើតនៅភ្នំក្រោម។

ក៖ ចុះអ្នកមីងមានបងប្អូនចំនួនប៉ុន្មាននាក់ដែរ?

ខ៖ បងប្អូន៥នាក់។

ក៖ ហើយមានប្រុសប៉ុន្មានស្រីប៉ន្មានដែរអ្នកមីង?

ខ៖ ស្រី២ ប្រុស៣។

ក៖ ចុះអ្នកមីងជាកូនទីប៉ុន្មានដែរអ្នកមីង?

ខ៖ ខ្ញុំជាកូនទី២។

កៈ ចុះអ្នកមីងអាចប្រាប់ឈ្មោះបងប្អូនទាំងអស់របស់អ្នកមីងបានទេ? ពីបងរហូតដល់ប្អូនគេបំផុត?

ខៈ បានតើ បងទី១ឈ្មោះជួន យ៉ាន ហើយទី២ខ្ញុំណឹងជួន យ៉េត ហើយទី៣ជួន វណ្ណៈ ទី៤ជួន វណ្ណេត ទី៥ជួន ណាត។

កៈ ឈ្មោះជួន ណាត?

ខៈ ចាស ព្រោះអីឈ្មោះត្រកូលជួនចាស។

កៈ ចុះកាលពីក្មេងៗអ្នកមីងចូលចិត្តធ្វើអ្វីខ្លះដែរជាមួយបងប្អូនរបស់អ្នកមីង?

ខៈ ដូចជាមិនទម្លាប់ចូលចិត្តធ្វើអីទេ ចូលចិត្តអីរៀនអីណឹងឯង ប៉ុន្តែដល់ដាច់អាពតមកខ្ញុំអត់បានរៀនរកស៊ីចិញ្ចឹមប្អូន។

កៈ ចុះកាលពីមុនប៉ុល ពតចូលមកណឹងអ្នកមីងរៀនថ្នាក់ទីប៉ុន្មានដែរ?

ខៈ ថ្នាក់ទី១។

កៈ ហើយកាលរៀនណឹងរៀននៅសាលាណាដែរមីង?

ខៈ រៀននៅសាលាភ្នំក្រោម។

កៈ អញ្ចឹងមកដល់ឥឡូវអ្នកមីងចេះអាន និង ចេះសរសេរអក្សរខ្មែរទេ?

ខៈ ចេះខ្លះដែរតែអត់ចេះប៉ុន្មាន ចេះមើលឈ្មោះខ្លួនឯងបន្តិចបន្តួច។

កៈ អញ្ចឹងពីមុនមកនៅភ្នំក្រោមនេះអ្នកមីងរស់នៅឯណាដែរមីង?

ខៈ នៅស្រុកកំណើតណឹងឯងចាស ដល់ពេលនៅភ្នំក្រោមនេះឯងទៅក៏ដូចខ្ញុំនិយាយចឹងឯងថា ដាច់លន់ ណុលចេះឯងមក ដល់សីហានុចប់ទៅមិនធ្លាក់លន់ ណុល ដល់ពេលធ្លាក់លន់ណុលមកក៏ពួកខ្ញុំក៏ចូលស្រុកវិញមក ដល់ចូលស្រុកវិញមកតែមកនៅភ្នំក្រោមតែអត់មានមុខរបររកទៅនាំបងប្អូនទៅទន្លេរកស៊ីហើយដល់ពេលណានៅៗហើយក៏សម័យនោះក៏ ដល់នៅៗទៅក៏ចេះតែរកស៊ីនិងស្រុកចុងឃ្មៀសណឹងឯង ដល់ពេលណាចង់មកនៅភ្នំក្រោមវិញគេអត់ឲ្យនៅគេថាដាក់ទ័ព្វទាហាន ទៅក៏នាំបងប្អូនចុះទៅទន្លេវិញរហូតទៅ។

ក៖ ចុះកាលសម័យប៉ុល ពតណឹងអ្នកមីងអាយុប៉ុន្មានដែរអ្នកមីង?

ខ៖ ខ្ញុំកាលអាពតប្រហែលជាអាយុ១១ ១២ឆ្នាំដែរ។

ក៖ ចឹងអ្នកមីងចាំទេថាដំបូងឡើយពេលដែលប៉ុល ពតចូលមកណឹងអ្នកមីងជម្លៀសទៅខាងណាដែរអ្នកមីង?

ខ៖ ប៉ុល ពតចូលមកហី?

ក៖ បាទ។

ខ៖ ប៉ុល ពតចូលមកនៅនេះ នៅនេះបាន២ឆ្នាំដែរនៅចុងឃ្មៀសនេះណា នៅចុងឃ្មៀសបាន២ឆ្នាំហើយក៏ក្រោយមកក៏គេប្រាប់ថាគេជម្លៀសទៅនៅក្រឡាញ់ ទៅនៅក្រឡាញ់បាន ក៏គេជម្លៀសទៅនៅក្រឡាញ់ឆ្នាំណឹងទឹកធំណាស់ឆ្នាំណឹងឆ្នាំមរមីណឹងទឹកធំ ហើយក៏គេជម្លៀសទៅខ្ញុំមានឪពុកមានម្ដាយតែឪពុកពិការ ប្អូនទើបតែមាន៩នាក់ទេ ហើយក៏ពេលគេការណ្ឌតការអីនេះឯងទៅអូសទៅអូសទៅតាមស្ទឹងក្រឡាញ់ ស្ទឹងក្រឡាញ់ឡើងទៅដល់ស្រុកក្រឡាញ់ហើយគេប្រាប់ថាឡើងទៅលើទៀតអត់ឲ្យនៅនេះទេខ្ញុំថាអរ ក៏នាំឪពុកម្ដាយលើកបងប្អូនឡើងនោះឯងលើកឪពុកឡើងដាក់ឡានយកទៅទៀត ទៅដល់គេចែកតាមភូមិគេថាខ្លះនៅភូមិនេះខ្លះនៅភូមិនេះក៏ខ្ញុំគេឲ្យនៅភូមិនេះនៅភូមិអី នៅភូមិស្អីទេភ្លេចបានហើយចាប់ដៃ អីនៅភូមិចាប់ដៃ ក៏នាំបងប្អូនទៅលើកឥវ៉ាន់ចុះទម្លាក់នៅនោះឯង ក៏មិត្តអាពតណឹងគេចេះតែតាមដានពេកគេថាឥវ៉ាន់ច្រើនឥវ៉ានច្រើនអ្នកមកមុនឥវ៉ាន់តិចៗទេបាត់ខ្លួនអស់ ចុះបើទម្រាំអ្នកមកក្រោយឥវ៉ាន់ច្រើនចេះតើគិតយ៉ាងម៉េច ក៏ឪពុកម្ដាយខ្ញុំបងប្អូនចេះតែភ័យក៏ឲ្យគេយកអីយកទៅក៏ឲ្យតែខោអាវទៅគេទៅគេក៏យកខោអាវទៅនៅសល់ខ្លះស្លៀកនិងខ្លួន ដល់ក្រោយមកគេប្រាប់ទៀតថាអត់ឲ្យនៅនេះទេឲ្យទៅមុនទៀត ក៏លើកឪពុកម្ដាយក៏លើកឪពុកដែលពិការទៅមុខទៀតទៅដល់ទៅមុខទៀតគេថានៅនេះហើយនៅភូមិខ្នាយជោរ ក៏នៅនៅភូមិណឹងឯងបានយូរក៏មិត្តនោះគេថាទៀតមានឥវ៉ាន់អីខ្លះទេយកមកដាក់រួមមកទៅក៏ម៉ែខ្ញុំប្រាប់ថាហីកូនឯងស្រលាញ់ខោអាវអីខ្ញុំថាអត់ស្រលាញ់អីទេម៉ាក់ ខ្ញុំស្រលាញ់ខោអាវខ្មៅចុះឃើញគេស្លៀកខ្មៅនោះ ចឹងទៅក៏អត់មានទេកូនចឹងខោអាវនេះឲ្យគេហើយណាចាស ហើយគេថាទៀតមានមាសប្រាក់អីដាក់ឲ្យគេឲ្យអស់មក ហើយខ្ញុំក៏ដាក់ម៉ែខ្ញុំគាត់ដាក់មាសឲ្យមួយប្រអប់ស្អីៗដាក់ឲ្យគេទាំងអស់ព្រោះគេថា គេប្រាប់ថាអ្នកមកមុនអត់មានខោអាវឥវ៉ាន់ច្រើនចឹងទេ អត់មានបាត់ខ្លួនអស់ហើយ ចុះបើទម្រាំអ្នកមកក្រោយអ្នកឯងមកថ្មីគេចាស់ណាគេងាប់អស់ហើយ តែអ្នក

ឯងមកថ្មីខោអាវច្រើន ឥវ៉ាន់ច្រើនចេះដឹងយ៉ាងម៉េច ទៅលើកដៃសំពះគេសុំឲ្យបានសុខ អ្នកឯងយកអីយកចុះតាំងពីមាសអីក៏ដោយឲ្យគេទាំងអស់ទាំងប្រអប់ៗ ទុកតែខោអាវ២ ៣បានហើយក៏ហី គីហីទៅខ្ញុំនេះគេអឺមិត្តឯងនេះអឺហើយបងស្រីខ្ញុំអត់មានឲ្យនៅជុំខ្ញុំទេគេឲ្យទៅនៅស្រុកឃ្លាំងបំបែកគ្នា ចាសគេបំបែកគ្នាឲ្យទៅនៅឃ្លាំងឯណោះខ្ញុំតាមម្ដាយទៅជាប់ទៅគេថាអឺមិត្តយ៉េតឯង ទៅក៏ថាមិត្តយ៉េតឯងអត់ឲ្យនៅជាមួយម្ដាយឪពុកទេឲ្យទៅនៅស្រែប្រាំង ក៏ខ្ញុំថាស្រែប្រាំងឯណាទៅស្រែប្រាំងនៅលើក្រឡាញ់ណោះ ក៏ខ្ញុំថាចាសខ្ញុំទៅក៏ទៅហើយក៏ចេញដំណើរទៅ ទៅដល់ស្រែប្រាំងនោះសុទ្ធតែ ម៉ាស្រករៗគ្នាហើយមានមិត្ត ហើយមានគេប្រធានមានអីចឹងមនុស្សច្រើនណាស់រាប់រយៈនៅកន្លែងស្រែប្រាំងណឹងសម្រាប់ធ្វើស្រែខ្ញុំក៏ទៅនិងគេដែរក៏ម៉ែឪនៅឯភូមិទៅ ដល់ទៅក៏ ខ្ញុំអត់ចង់និយាយទេកំសត់ទៅមានអឺមានបងប្រុស ប្រុស២ស្រី២នាក់ទៅពីសៀមរាបដែរគេឃើញខ្ញុំគេអាណិតគេថាណោះ មិត្តឯងចាំធ្វើការជាមួយខ្ញុំមកមិនបាច់ទៅជុំជាមួយគេទេ ខ្ញុំថាឲ្យខ្ញុំទៅធ្វើអីគេថាមិនបាច់សួរទេចាំទៅជាមួយខ្ញុំទៅបានហើយ ហើយបាយអីហូបជាមួយខ្ញុំមិនបាច់ហូបជាមួយគេទេ ក៏គេឲ្យពួកគេទៅប្រជុំខ្ញុំអត់បានទៅប្រជុំទេ ស្រាប់តែក្រោកពីយប់ឡើងគេនាំគ្នាក្រោកទៅស្រែ គេរ៉ៃជួងម៉ឹងៗគេនាំគ្នាក្រោកទៅស្រែទៅគេរងាគេមួយចេះឯងទៅខ្ញុំថា អញអត់បានទៅនិងគេទេអញដេកហើយចុះបងគាត់ថាមិនបាច់ក្រោកនិងគេទេហ្អែងដេកទៅចាំតែភ្លឺឡើងធ្វើការជាមួយខ្ញុំខ្ញុំថាចាសអរបងចាស ក្រោយមកគេក៏ទៅស្រែអស់ទៅគេនាំគ្នាតម្រង់ជួរទៅស្រែអស់ហើយនៅតែខ្ញុំ នៅតែខ្ញុំភ្លឺឡើងខ្ញុំក្រោកក្រោកទៅ បងធម៌ណឹងឯងគាត់អាណិតគាត់ថានែអូនឯងយកកាតូមួយទៅធុងមួយដងទឹកជះស្រែហើយបាយតិចទៅ បាយកកនៅយកទៅហូបទៅ ចាសបងក៏ទៅតាមគាត់ក៏ដើរតាមគាត់ហើយទៅចឹងទៅ គាត់ថាជះស្រែទៅអាត្រង់ណាដែរដើរៗនោះវាអត់មានទឹក ខ្ញុំក៏ធ្វើតាមគាត់ណឹងឯងក៏ដើរជះ ក៏ជះទៅដល់ថ្ងៃឡើងវាក្ដៅពេក ខ្ញុំដេកក្រោមដើមឈើដេកក្រោមដើមឈើទៅក៏ ប្រហែលជាគាត់ឃើញខ្ញុំឃើញខ្ញុំដេកក្រោមដើមឈើគាត់អាណិត គាត់នាំគ្នា គ្នាគាត់២នាក់ណឹងឯងគាត់ទៅកាប់ដំបូក កាប់ដំបូកមួយធំ ឯលើនោះកាប់ព្រៃអាព្រៃលើៗនោះឲ្យខ្ញុំអង្គុយក្នុងដំបូកលើកដំបូកនោះឯង គាត់ថាបងកាប់អាដំបូកខាងលើនោះឲ្យអង្គុយហើយណាកុំដេកតាមវាលស្រែទៀតណា ចាសក៏ខ្ញុំឡើងដេកលើដំបូកណឹងឯង គាត់ប្រាប់ថាបើសិនជាគេមកស្ទួងមកដកនៅនេះ កុំចេញឲ្យគេឃើញណាប្រយ័ត្នគេច្រណែនគេថាយើងបក្សពួកខ្ញុំថាចាស ពេលគេមកស្ទូងដកជិតចេះខ្ញុំអត់ហ៊ានចេញទេ សុខចិត្តគាត់យកបាយមកឲ្យហូបកុំឲ្យគេច្រណែនគេថាយើងស្រណុកជាងគេ ក៏បានគាត់ណឹងឯងចេះតែមើលឲ្យស៊ីឆ្អែតៗតែក្រៅពីនោះគេស៊ីអត់ឆ្អែតទេបបរមួយវែកហើយអត់មានត្រីទេមានតែអំបិលហើយខ្ញុំថ្ងៃឡើងទំនេរចេះស្ទាត់ពីគេ នាំគ្នាទៅម្នាក់ឯងទៅបោចត្រីក្នុងលូ ចូលក្នុងលូបានត្រី

បានយកមកប្រឡាក់ ប្រឡាក់ហើយហាលហាលបានគេមកពីធ្វើស្រែវិញដើរហុចគេឲ្យគេយកទៅដុតទៅហូបទៅព្រោះខ្ញុំមានម្ហូបហើយដល់ក្រោយមកថាក្រោយមកបានប្រហែលប៉ុន្មានខែទេ ក្នុងមួយអាទិត្យគេឲ្យយើងមកលេងម៉ែឪនៅឯភូមិម្តង ក៏នាំបងប្អូនដើរមកហើយមកលេងម៉ែឪនៅឯភូមិណោះ មួយអាទិត្យគេឲ្យមកម្តង ក៏នាំបងប្អូដើរកាត់វាលស្រែមក ដល់ពេលក្រោយមកលឺសូរហើគេថានែមិត្តឯងធំៗនេះតិចទៀតគេយកទៅនៅក្នុងភ្នំទ្រុងបាតហើយខ្ញុំថាអឺ ទៅភ្នំទ្រុងបាតធ្វើអីមិត្ត ទៅគេថាទៅឲ្យមិត្តឯងនៅនោះស្រួលហើយ អរចឹងហីស្រួលជាងនេះទៀត ប៉ុន្តែការពិតអត់មែនទេខ្ញុំអត់ដឹងទេទាល់តែពេលដាច់វៀតណាមបានដឹងគេយកទៅដុត គេយកទៅដុតដល់ពេលក្រោយមកដល់ពេលក្រោយមកក៏ វៀតណាមចូលមកដល់វៀតណាមចូលមកបានដឹងខ្លួនថាភ្នំទ្រុងបាតនោះគេដុតមនុស្ស បើកុំតែវៀតណាមចូលមកទាន់ណាត្រូវពួកខ្ញុំនេះគេឲ្យគេយកទៅដុតមុនគេហើយគេឲ្យកុមារទៅមុនគេ កុមារគេហៅយើងកុមារជំទើរ ប៉ុន្តែដល់ពេលវៀតណាមចូលមកនោះឯងទៅ ទាន់ក៏បានដឹងខ្លួនថាអរអញចេះតើបើថាយូរតិចទៀត ដល់ពេលវៀតណាមចូលមក វៀតណាមចូលមក វៀតណាមវាបាញ់ដេញអាពតទៅនៅភូមិនោះគេប្រាប់ថា យើងត្រៀមខ្លួនរត់ចេញនៅក្នុងភូមិនេះអត់បានទេព្រោះអីវៀតណាមគេចូលមកហើយយួនគេចូលមកហើយគេដេញអាពតហើយ តើយើងត្រូវរត់ទៅណាយើងថាហី រត់គេចពីភូមិសិនខ្លាចពួកគេគៀរខ្លាចអាពតណឹងគេគៀរប្រជាជនឡើងទៅអន្លង់វែងក៏នាំបងប្អូនទៅពួនក្នុងព្រៃទាំងអស់គ្នានោះឯងគេទុកតែឪពុកទេដែលទៅអត់រួចនៅចាំផ្ទះដល់ពេលភ្លឺឡើងក៏ស្ងាត់ទៅដល់ស្ងាត់ទៅក៏ចូលស្រុកវិញទៅ ចូលស្រុកវិញទៅក៏ស្រាប់តែវៀតណាមវាបាញ់ដេញ វាបាញ់វាបាញ់ពីថ្នល់ជាតិមកចុះយើងនៅលើថ្នល់ជាតិវាបាញ់ អូ!

និយាយថាពីគ្រាប់អូនអើយដូចលៀច ដូចលៀចចេះឯងក៏ខ្ញុំនេះឯងវាល្ងង់ដឹងជាឆក់បានអីបានអង្ករមួយចំហៀង បានអាក្រណាត់នោះមួយចំហៀងរែកក្រណាត់យកទៅពាក់ រែករត់រែករត់ក៏ឪពុកអីអត់ទៅទេខ្ញុំថាអរពុកអើយពុកឯងមកៗ ថាអត់ទៅទេកូន បើពុកឯងមិនទៅស្លាប់ហើយត្រូវតែមកៗទៅអត់រួច ចុះក៏នាំគ្នារែករែករត់សិន នាំបងប្អូនអ្នកស្រុកណឹងឯងនាំគ្នារែករែករត់ឡើងមកថ្នល់ជាតិ ដល់ពេលណាស្ងប់គ្រាប់ឯង ថានាំគ្នាទៅមើលឪពុកថាម៉េចហើយទេមិនសង្ឃឹមទេព្រោះអីគាត់ដើរមិនរួចគាត់ស្ពឹក គាត់អត់កើតអីទេគាត់ស្ពឹកគាត់ចាក់ថ្នាំតែមួយម្ភុលសោះគាត់ដើរអត់រួច ក៏ទៅមើលៗឃើញគាត់នៅនៅឯងគាត់ថាកូនអើយអត់អីទេអញ ក៏កៀកករគាត់រករទេះដឹកគាត់មកមកថ្នល់ជាតិព្រោះយើងមកសៀមរាបវិញ ដល់តែថាមកដល់ថ្នល់ជាតិជុំគ្នាហើយក៏ ដើរ ដើរខ្ញុំនេះបីប្អូន ឪពុកនោះគាត់មានឈើច្រត់ គាត់មានឈើច្រត់គាត់ដើរៗពីក្រឡាញ់មក ដើរពីក្រឡាញ់មកដល់ដល់នៃ ភូមិអីគេទេត្រង់ណោះឯងដូចថាចេញទៅចេះតែដើរមកទៀតទាំងយប់ទាំងថ្ងៃអត់មានសម្រាកឯណាទេចេះដើរមកអូមកសម្រាកនៅ

ពួក ដល់ពួកងងឹតហើយឃើញពួកមានមនុស្សច្រើនមានផ្ទះសម្រាកអីក៏សុំ សុំឲ្យពុកម៉ែសម្រាក សម្រាកនោះបានមួយយប់ អរចេញមកទៀតក្រោកពីយប់ដើរទៀតមិនមែនដើរតែយើងទេមានគេមានឯងដែរ ទូលក៏ទូលរែកក៏រែកទៅខ្ញុំក៏បីប្អូនផងក៏រែកខោអាវផង ដើរៗទៅមកដល់សៀមរាបដល់សៀមរាប ដល់វត្តស្វាយមកដល់វត្តស្វាយឃើញផ្ទះគេទំនេរក៏សុំសម្រាកនៅផ្ទះនោះឯង ផ្ទះណឹងឯងលឺគេថានៅវត្តស្វាយមានស្រូវក៏នាំបងប្អូនទៅច្រូតស្រូវច្រូតស្រូវគេបានប៉ុន្មានការ៉ុង ៤ ១០ ២០ការ៉ុងនោងឯងក៏ យកមកកិនយកមកដាល់អីហូបទៅណាព្រោះកាលនោះយើងអត់ទាន់មានអីទេ ចាសមិនទាន់បានចុះមកទន្លេវិញទេព្រោះអីឥវ៉ាន់ទៅពីនេះៗគ្រាន់តែឥវ៉ាន់ទៅពីនេះណា២គោយន្តដល់មកវិញម្នាក់តែមួយអង្រែកទេ ក៏ដងរែកនៅតើកញ្ជើរនៅមកវិញក៏អស់អីទៅក៏បានកណ្ដៀរយកមកពីនោះឯងបានកណ្ដៀរ ចេះយកមកតាមបានកណ្ដៀរណឹងឯងច្រូតស្រូវច្រូតអីបានណឹងឯងក៏នាំគ្នារកត្បាល់រកអីបុកបានអង្ករ បបរៗ បបរទៅបានច្រើនក៏ដាំបាយចែកគ្នាហូបទៅ ហើយទៅក្រោយមកលឺគេថានៅចុងឃ្មៀសស្វាត់ណាស់ យើងទៅរកនៅស្រុកទៅខ្លាចយើងនៅផ្ទះនេះគេមកផ្ទះគេគេមកគេរកផ្ទះគេហើយព្រោះយើងនៅនេះជាប់មិនបានទេក៏នាំគ្នាក្រោកពីយប់ដើរទៀតហើយដើរទូលរែកមកមកដល់ចុងឃ្មៀសនេះឯងទៅដល់មាត់ទន្លេឯណោះ ដើរទៅដល់បោះជំរុំនៅអត់ទាន់មានអីទេណា យើងនៅលើថ្មល់សិនទៅនៅលើដីចឹងសិនទៅដូចអត់ទាន់មានមុងមានកន្ទេលមួយដែរកន្ទេលវាយកមិនបានច្រើនទេ វាបានកន្ទេលណឹងឯងមកពីក្រឡាញ់ យួរបានកន្ទេលមួយណឹងឯងដល់ក្រោយមកក៏ចេះតែរកទៅតិចៗៗទៅល្បីទៅបង ល្បីទៅបងថារៀតណាមដេញអាពតអត់ហើយក៏បងនោះមកពីឃ្លាំងដើរដែរ ដើរមកជួបគ្នានៅវត្តស្វាយបានជាធ្វើដំណើរចេះមកចុះមកជុំគ្នាទាំងអស់គ្នាណឹងឯងខាងណោះគេដើរមកពីឃ្លាំងពួកខ្ញុំតូចៗនេះដើរមកពីក្រឡាញ់ ចាសពួកគេគេហៅនារីណានារីគេដើរមកពីឃ្លាំងនោះជុំគ្នាឯងដើរមកពីនោះ មកពីក្រឡាញ់ណឹងឯងជុំគ្នាទៅ បងខ្ញុំនោះកាលនោះគេធំជាងខ្ញុំក្រោយមកក៏បានទៅសុំទូកអ្នកឃ្លាំងទៅសុំទូកអ្នកឃ្លាំងបានមួយស្គាល់នោះសុំគេបានមួយក៏បានទូកណឹងឯងចេះតែវាយមងអីទៅសុំមងសុំអីព្រោះអីនៅឃ្លាំងគេអត់ជម្លៀសទេ គេអត់ជម្លៀសទៅណាឥវ៉ាន់នៅច្រើនណាស់នៅឃ្លាំងច្រើនណាស់ដាច់ចិត្តសុំមងគេបាន២ ៣ដៃទូកនោះឯងខ្ញុំក៏ចុះទៅវាយមងជាមួយពុកប្អូននៅតូចពេកទៅ២នាក់ពុក ពុកដោះមងទៅខ្ញុំធ្វើត្រីក៏មិនទាន់លក់ឲ្យអ្នកណាមានស៊ីទេព្រោះមិនទាន់បានទិញចេញចូលទៅណាទេគ្រាន់តែបានមួយហូប អត់បានលក់ដូរអីទេព្រោះនៅច្របល់ មិនទាន់មានទីផ្សារទេបានមួយឆ្នាំឡើងបាន បានមានគេចេះទិញគ្នាទៅវិញទៅមកបានហូបប្រវិត្តគ្រួសារខ្ញុំកំសត់ណាស់។

កៈ ចុះម្ដាយអ្នកមីងមានឈ្មោះអ្វីដែរមីង?

ខៈ ម្ដាយខ្ញុំឈ្មោះឌិន ធន័។

កៈ ចុះឪពុកអ្នកមីងឈ្មោះអ្វីដែរ?

ខៈ ឪពុកខ្ញុំឈ្មោះជួន ណាំង។

កៈ ចុះពួកគាត់ទាំងពីរនាក់មានស្រុកកំណើតនៅឯណាអ្នកមីងដឹងទេ?

ខៈ ឪពុកខ្ញុំអ្នកស្រុកនេះឯងម្ដាយខ្ញុំអ្នកស្រុកនេះឯង។

កៈ ចុះពួកគាត់ទាំងពីរណឹងប្រកបការងារអ្វីដែរដើម្បីចិញ្ចឹមជីវិតពេលដែលមីងនៅក្មេង?

ខៈ នៅស្រុកនេះឪពុកខ្ញុំគាត់ គាត់លេងភ្លេងចាសគាត់គ្រូភ្លេងគ្រូភ្លេងគ្រូភ្លេងពិនពាត។

កៈ ចុះម្ដាយអ្នកមីងវិញនោះ?

ខៈ ម្ដាយខ្ញុំនៅផ្ទះគ្មានមុខរបរអីទេ។

កៈ ចុះឪពុកអ្នកមីងចេះលេងភ្លេងអ្វីខ្លះដែរអ្នកមីង ចេះទាំងអស់ហី?

ខៈ ចាស ចេះទាំងអស់។

កៈ ចុះអ្នកមីងមានចេះទេ?

ខៈ ខ្ញុំអត់ចេះទេខ្ញុំចេះតែស្ដាប់ដឹងតែស្ដាប់ពិរោះតែខ្ញុំអត់ចេះទេ។

កៈ អត់បានរៀនពីឪពុកទេ?

ខៈ ចាស ចាស។

កៈ ចុះម្ដាយអ្នកមីងណឹងគាត់ជាមនុស្សបែបណាដែរ? គាត់កាចឬក៏គាត់ស្លូតដែរ?

ខៈ ម្ដាយខ្ញុំកាចដែរ កាច។

កៈ ចុះឪពុករបស់អ្នកមីងវិញ?

ខ៖ ឪពុកខ្ញុំស្លូតទេ។

ក៖ ចុះឪពុកម្ដាយអ្នកមីងធ្លាប់សាច់រឿងរបស់គាត់កាលពីក្មេងៗដល់មីងទេ?

ខ៖ គាត់ប្រាប់ដែរថាគាត់ជំនាន់ដើមគាត់លំបាកណាស់លំបាកណាស់ជំនាន់រាស្ត្រនិយមជំនាន់សីហនុគេហៅជំនាន់សីហនុ ពិបាកណាស់កូនពិបាកម៉េចសម័យនោះម៉ូតូក៏គ្មាន ម៉េញ៉ៅក៏គ្មាន ទូរស័ព្ទក៏គ្មាន សូម្បីតែកង់ក៏គ្មានបើសិនជាអ្នកណាគេមានម៉ូតូមួយ គេមានម៉ាញ៉ៅស្ដាប់មួយគេមានកង់មួយអាណឹងគេគ្រាន់ហើយ ចាសតែគាត់មានត្រឹមតែកង់ទេ ដល់គាត់ចាប់ដៃបានគ្នាណា ចាសទៅក៏កំសត់ណាស់ គាត់មានកង់នោះសម្រាប់ជិះទៅលេងភ្លេងហើយម៉ែខ្ញុំក៏នៅផ្ទះទៅមើលកូនទៅ។

ក៖ ចុះអ្នកមីងនៅចាំឈ្មោះជីដូនជីតាខាងម្ដាយទេអ្នកមីង?

ខ៖ ចាំតើ។

ក៖ បាទគាត់ឈ្មោះអ្វីដែរមីង?

ខ៖ ឈ្មោះលោកយាយជុំ  លោកតាឈ្មោះលោតាឌិន។

ក៖ ចុះខាងឪពុកវិញអ្នកមីង?

ខ៖ ជីតាឈ្មោះជូន រីក ដល់យាយយាយឈ្មោះមិនដឹងឈ្មោះស្អីរីក យាយឈ្មោះសាំងតែមិនដឹងនាមត្រកូលគាត់ស្អីសាំងទេណា។

ក៖ ចុះពួកគាត់ក៏មានស្រុកកំណើតនៅចុងឃ្មៀសនេះដែរមែនមីង?

ខ៖ ចាស ចាសនៅភ្នំក្រោមដល់ពេលណាឆេះផ្ទះអស់ទៅធ្លាក់ខ្លួនទៅនៅទន្លេដែរ។

ក៖ ចុះកាលអ្នកមីងកើតមកណឹងអ្នកមីងទាន់យាយតាតើហីអ្នកមីង?

ខ៖ ទាន់។

ក៖ ចុះអ្នកមីងចាំអ្វីខ្លះដែរពីជីដូនជីតាអ្នកមីង?

ខ៖ ចាំបានតិចៗដែរ សួពីប្រវិត្តដែលគាត់រកស៊ីឬក៏សួរពីម៉េច?

កៈ បាទអ្វីដែលអ្នកមីងចាំពីគាត់អ្នកមីងអាចនិយាយប្រាប់បាន។

ខៈ គាត់ពីដើមគាត់ធ្វើថ្មនៅជើងភ្នំ ពីដើមនៅស្រុកភ្នំគេធ្វើតែថ្ម ធ្វើថ្មលក់ឲ្យជប៉ុនណា ចាសធ្វើថ្មលក់ឲ្យជប៉ុនយាយតាទាំងអស់គ្នាណឹងឯងលីស្វរគាត់និយាយថាធ្វើថ្មមុខរបរ ដល់ស្រែគាត់ធ្វើស្រែទៅដល់មកពីស្រែគាត់ធ្វើស្រែទៅ។

កៈ តែប៉ុណ្ណឹងទេអ្នកមីង?

ខៈ ចាសអស់។

កៈ ចុះអ្នកមីងមានបងប្អូនឬក៏សាច់ញាតិដែលរស់នៅក្រៅប្រទេសទេមីង?

ខៈ ខ្ញុំអត់មាន។

កៈ ចុះស្វាមីរបស់អ្នកមីងមានឈ្មោះអ្វីដែរមីង?

ខៈ ខ្ញុំអត់មានទេ។

កៈ អ្នកមីងអត់មានគ្រួសារទេ?

ខៈ ចាស។

កៈ ចុះអ្នកមីងមានមិត្តភិក្តដែលធំធាត់ស្និតស្នាលមកជាមួយគ្នាទេអ្នកមីង?

ខៈ នៅស្រុកខ្មែរនេះហី?

កៈ បាទអ្នកមីង។

ខៈ ខ្ញុំដូចជាអត់មានទេគេរាប់អានខ្ញុំដែរខ្ញុំក៏រាប់អានគេប៉ុន្តែមិនចាត់ទុកថាមិត្តភិក្តព្រោះអីខ្ញុំមិនសូវចូលចិត្ត មានមិត្តភិក្តម្នាក់ដែរតែចិត្តអត់ត្រង់ខ្ញុំក៏ឈប់រាប់អានរហូតទៅ ចិត្តអត់ត្រង់នោះមិនមែនចិត្តរឿងអីទេខ្ចីខ្សែដៃខ្ញុំ៣ជីមាសអត់ឲ្យខ្ញុំវិញទេខ្ញុំខឹងខ្ញុំអន់ចិត្តខ្ញុំឈប់ ឈប់និយាយរកហើយក៏ខ្ញុំឈប់ដើរជាមួយខ្ញុំដឹងថាមនុស្សណឹងចិត្តមិនត្រង់

កៈ ចុះអ្នកមីងមានមិត្តភិក្តដែលស្និតស្នាលដែលរស់នៅក្រៅប្រទេសខ្មែរមានអត់មីង?

ខ៖ ខ្ញុំមានម្នាក់ឈ្មោះនៅ បងនៅគាត់មកគាត់មកញុំបបរខ្ញុំទៅខ្ញុំបបរលក់នៅមុខផ្ទះណា គាត់មកគាត់មកញុំបបរខ្ញុំស្មានតែគាត់នៅភ្នំពេញ គាត់ក៏ប្តីគាត់ គាត់ ក្មួយគាត់ ម៉ាក់គាត់ គាត់ចូលញុំបបរខ្ញុំថាញុំទៅបងខ្ញុំស្មានតែគាត់នៅភ្នំពេញដល់និយាយយូរៗបងនៅប្រទេសក្រៅតើ ចុមហើយយាយគាត់ថាចង់ញុំត្រីចង់ញុំត្រីក្អែតស្ងោរ អូ!ខ្ញុំថាចុះបើយាយចង់ញុំត្រីក្អែតស្ងោរនៅស្តង់គេមានលក់ ចឹងចាំខ្ញុំជូនទៅទិញឲ្យយកមកស្ងោរហូបបាយនៅផ្ទះខ្ញុំនេះហើយ ចឹងក៏ចឹងទៅគាត់ក៏ឲ្យទៅទិញត្រីទិញអីយកគ្រឿងយកមកស្ងោរគាត់ក៏អង្គុយលេងនៅផ្ទះណឹងឯង ទាំងយាយទាំងបងនៅទាំងប្តីគាត់នោះឯង គាត់ក៏និយាយថាអឺយ៉េតអើយ បងសូមអង្វរណាអីបើឈឺសម្រាកកុំខំលក់ណាប្រយ័ត្នឈឺគ្មានអ្នកមើលយើងទេហើយបើអូនឯងអត់លុយចាំតែទៅបងទៅចាំបងវេរមកឲ្យតិចតួចគ្រាន់មើលខ្លួន ដល់ពេលក្រោយមកខ្ញុំអត់មានទូរស័ព្ទទេដល់ម្នាក់នោះគេមានទូរស័ព្ទ គេក៏យកលេខណឹងឯងចុចទៅមកវិញឃើញ ឃើញគេប្រាប់និយាយជាមួយគ្នាបានប៉ុន្មានថ្ងៃដែរស្រាប់ឯណោះគេថាអ្នកនៅយើងនេះគេថាដូចថាមិត្តភិក្តចុះទូរស័ព្ទខ្ញុំបាត់ៗទៅហើយកូនខ្ញុំ ទូរស័ព្ទកូនខ្ញុំបាត់ហើយអត់មានអីនិយាយទេបងឯងរកអីនិយាយរកទៅខ្ញុំថាអររអញ្ចឹងហេ តាំងពីនោះមកខ្ញុំអត់មានអីនិយាយទេ ខ្ញុំអត់មានអីនិយាយទេក៏អត់ទៅ មិនដែលបានជួបគាត់ទេហើយគាត់ក៏មិនដែលបានថា ដែលនិយាយនោះមិនមែនវេរលុយមកឲ្យភ្លាមទេណាគ្រាន់តែនិយាយសួរសុខទុក្ខណា នៃយ៉េតនេះផ្ទះខ្ញុំ គាត់នៅអឺអាគាំងជនជាតិអាគាំង។

ក៖ សហរដ្ឋអាមេរិក។

ខ៖ ចាស ទៅខ្ញុំអត់មានទូរស័ព្ទអីនិយាយទៅកាន់គាត់ទេតាំងពីនោះមក ក៏អត់ទៅដល់មិត្តភិក្តខ្ញុំឥលូវដែលថាមិត្តភិក្តចុះ ម្នាក់ណឹងឯងដែលថាកូនបាត់ទូរស័ព្ទនេះណាដល់ឥឡូវគេលែងនិយាយរកខ្ញុំហើយ គេលែងនិយាយរកខ្ញុំព្រោះគេមានណា គេនិយាយគេថាគេមិនដើរជាមួយខ្ញុំទេគេដើរជាមួយអ្នកមានវិញសប្បាយចិត្តជាង ដើរជាមួយខ្ញុំអ្នកក្រអត់សប្បាយចិត្ត ទៅខ្ញុំចាំថាអរប្រហែលជាគេអត់ដើរជាមួយអញអញក្រតាំងពីនោះមកខ្ញុំឈប់ ឈប់ឡើងចុះផ្ទះគេ ទៅដល់ពេលណាខ្ញុំចង់និយាយទៅគាត់ក៏គ្មានអីនិយាយដែរតែខ្ញុំអត់ប្រាប់បងប្អូនទេខ្ញុំខ្លាចរឿងណឹងវាអត់ពិត អត់ប្រាប់ទេខ្ញុំឲ្យតែម្នាក់ឯងណឹងដឹង ដល់ឥឡូវគេឈប់និយាយរកខ្ញុំក៏ខ្ញុំក៏ឈប់បាននិយាយទៅបងនៅទៀតនោះឯង។

ក៖ ចុះអ្នកមីងតាំងពីក្មេងដល់ឥឡូវតើអ្នកមីងធ្លាប់ប្រកបការងាអ្វីខ្លះដែរដើម្បីចិញ្ចឹមជីវិត?

ខ៖ ខ្ញុំវាយមង វាយមង វាយមងទៅដល់ពុកខ្ញុំគាត់អត់ទៅជាមួយខ្ញុំអត់ហ៊ានទៅវាយទៀតខ្ញុំខ្លាច ខ្លាចគេធ្វើបាប ក្រោយមកក៏ខ្ញុំលក់នំបញ្ចុក នៅទន្លេលក់នំបញ្ចុកអ៊ុំទូក លក់នំបញ្ចុកដល់ពេលលក់ហើយអីហើយចឹងទៅ ដល់ពេលឥឡូវនេះលឺសូរថាគេចែកដីណាដីតាមថ្នល់នេះដីរដ្ឋបើអ្នកណាបាននៅអ្នកនោះយកទៅ អញ្ចឹងក៏នាំម៉ែកូនណឹងមកបោះធ្វើជាផ្ទះនៅទៅ បើយើងមិននៅគេនៅហើយដីរដ្ឋគេឲ្យណាខ្ញុំក៏ខាននៅទន្លេទៅមកនៅ នេះនៅជើងមកនៅត្រង់ណោះឯង នៅនិងគេទៅក្រោយមកក៏ម្តាយខ្ញុំស្លាប់ហើយកាលដែលម្តាយខ្ញុំនៅរស់ ខ្ញុំធ្វើការឲ្យគេដល់ខ្ញុំទៅអត់ទាន់អត់ទាន់គេណាគេកាត់ពេក គេចេះតែកាត់ពេៗខ្ញុំឈប់ ខ្ញុំឈប់នៅផ្ទះមើលម្តាយម្តាយជរាដល់ម្តាយខ្ញុំខូចទៅនៅតែឪពុកឥឡូវពុកទៅបួសទៀត ពុកខ្ញុំគាត់ប្រាប់ថាពុកទៅបួសហើយកូនឯងនៅផ្ទះទៅមើលផ្ទះបើពុកនៅផ្ទះក៏រស់មិនបានយូរ ចឹងហើយពុកទៅបួសចុះបើស្លាប់ស្លាប់និងបួសចុះ។

ក៖ ចុះក្នុងជីវិតរបស់អ្នកមីងតើពេលណាដែលអ្នកមីងគិតថាជាពេលដែលអ្នកមីងសប្បាយចិត្តជាងគេដែរ?

ខ៖ ខ្ញុំរកពេលសប្បាយអត់ឃើញទេព្រោះអីជីវិតរបស់ខ្ញុំវាពោរពេញទៅដោយទុក្ខលំបាក ខ្លួនទីពឹងខ្លួនមិនដឹងថាទៅពឹងអ្នកណាឲ្យបានសប្បាយចិត្ត។

ក៖ ចុះកាលមីងនៅក្មេងណឹងអ្នកមីងធ្លាប់មានក្តីស្រម៉ៃថាពេលធំឡើងអ្នកមីងចង់ធ្វើអ្វីទេមីង?

ខ៖ ចង់ដែរ ថាក្តីស្រម៉ៃធំឡើងចង់ដេរតែទីបញ្ចប់អត់បានដេរទេ រកស៊ីចិញ្ចឹមប្អូនព្រោះប្អូននៅតូច ពុកខ្ញុំគាត់ចូលពីអាពតមកគាត់ជាជើងវិញគាត់ដើរបាន ចាសអត់បានលេបថ្នាំទេគាត់ដើរបាន គាត់ដើរបាននោះឯងក៏ខ្ញុំជាមួយនោះឯងវាយមងចិញ្ចឹមប្អូនចិញ្ចឹមម្តាយ ចិញ្ចឹមបង បងនៅមើលម្តាយយើងទៅវាយមងជាមួយឪពុកទៅ ឲ្យបងនៅមើលម្តាយគ្រាន់ឲ្យមើលប្អូនផងខ្ញុំអ្នករកមកពីព្រៃពីរនាក់ពុក។

ក៖ ចុះអ្នកមីងចូលចិត្តពិសារម្ហូបអ្វីជាងគេដែរអ្នកមីងតាំងពីក្មេងដល់ឥលូវណា?

ខ៖ ខ្ញុំចូលចិត្តហុង ហុងជើងជ្រូក។

ក៖ បាទ មានអ្វីផ្សេងទៀតទេ?

ខ៖ ឬក៏ស្ងោរជើងជ្រូកអីទៅពេលដែលយើងញុំាទៅវាមានកម្លាំងណាវាមានជាតិនេះពិសេសចាស។

កៈ បាទអ្នកមីងចុះអ្នកមីងមានចូលស្តាប់ចម្រៀងអីទេមីងកាលពីក្មេងៗ?

ខៈ ចូលចិត្តដែរដល់ឥឡូវក៏ដោយក៏ចូលចិត្តដែរ ចូលចិត្តអឺបទសម័យមុនចាស អឹម យ៉េន ស៊ិន ស៊ីសាមុត រស់ សេរីសុទ្ធាខ្ញុំចូលចិត្តណាស់ ប៉ែន រ៉ននមិនសូវចង់ស្តាប់ទេ ចូលចិត្តស្តាប់រស់ សេរីសុទ្ធា។

កៈ ចុះកាលពីនៅក្មេងអ្នកមីងធ្លាប់បានលេងល្បែងប្រជាប្រិយអ្វីទេមីងពេលចូលឆ្នាំអី ម្តងៗណា។

ខៈ លេងតើ។

កៈ លេងអ្វីខ្លះដែរមីង?

ខៈ លេងបោះអង្គុញ លេងចោលឈូង ហើយលេងទាញព្រាត់ ហើយលេងអឺអាស្តេច ខ្ទង់ទៀត ចាសលេងល្បែងណឹងឯងតែបៀរអត់ចេះលេងទេ។

កៈ អញ្ចឹងមកដល់ចុងបញ្ចប់នេះតើអ្នកមីងមានអ្វីចង់ផ្តាំផ្ញើកូនចៅជំនាន់ក្រោយទេអ្នកមីង? ថាតើពួកគេគួរតែរស់នៅបែបណា ឬក៏ធ្វើជាមនុស្សបែបណាដែរអ្នកមីង?

ខៈ ខ្ញុំដូចមិនសូវចេះនិយាយខ្ញុំចង់និយាយថាចង់ផ្តែផ្តាំឲ្យកូនៗសាក្រោយឲ្យមាន គំនិតល្អគំនិតល្អណឹងគនិតយ៉ាងម៉េចកុំជក់ កុំផឹក កុំដើរលេងខុស ខុសប្រពៃណីណាហើយឲ្យកាន់ព្រះពុទ្ធសាសនាខ្មែរនិងគោរពប្រពៃណីខ្មែរព្រោះយើងកើតមកជាកូន ខ្មែរ។

កៈ បាទមានអ្វីទៀតទេអ្នកមីង?

ខៈ ខ្ញុំអត់សូវចេះនិយាយខ្ញុំអត់ចេះអក្សរ។

កៈ បាទអរគុណច្រើនអ្នកមីង អញ្ចឹងខ្ញុំសូមជូនពរឲ្យអ្នកមីងមានសុខភាពល្អ សំណាងល្អ និងមានសុភមង្គលណាមីងដែលបានចំណាយពេលវេលាសម្ភាន៍ជាមួយខ្ញុំ។

ខៈ ចាស។

កៈ បាទមីង។